**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអភិវឌ្ឍន៍ជនបទ**

**នាយកដ្ឋានសវនកម្មផ្ទៃក្នុង**

**លេខ :................ ស.ផ.ក**

ថ្ងៃពុធ ១៥ រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០២២

# របាយការណ៍សកម្មភាពការងារប្រចាំឆ្នាំ ២០២២ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង

## I. ស្ថានភាពទូទៅ

នាយកដ្ឋានសវនកម្មផ្ទៃក្នុង មានមន្ត្រីសរុបចំនួន ២៧ រូប (ស្រី ០៩ រូប) ៖

- ចំនួនមន្ត្រីរាជការ ដែលស្ថិតក្នុងភាពទំនេរគ្មានបៀវត្សរ៍ៈ គ្មាន
- ចំនួនមន្ត្រីរាជការ ដែលបានទៅបំពេញបេសកកម្មនៅក្រៅប្រទេសៈ ០១ រូប
- មន្ត្រីរាជការ សម្រាកលំហែមាតុភាពៈ គ្មាន
- ចំនួនមន្ត្រីរាជការ ដែលបានសហប្រតិបត្តិការជាមួយអង្គការ និងកម្មវិធី ៖ ០១ រូប
- ចំនួនមន្ត្រីរាជការ ស្ថិតនៅក្នុងស្ថានភាពទំនេរពីការងារៈ គ្មាន

## II. លទ្ធផលការងារ

### 1. ការងារសវនកម្មអង្គភាពថវិកា និងការងារសវនកម្មគម្រោង

**1.1. ការងារសវនកម្មអង្គភាពថវិកា ÷** នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានចុះធ្វើសវនកម្មលើថវិកាកម្មវិធីបានចំនួន ២៤ ខេត្ត និង ០១ រាជធានីគឺ ក្រចេះ ស្ទឹងត្រែង ព្រះវិហារ កំពង់ធំ រតនគិរី មណ្ឌលគីរី កំពត តាកែវ ប៉ៃលិន បាត់ដំបង ពោធិ៍សាត់ កោះកុង ខេត្តព្រះសីហនុ កំពង់ស្ពឺ កែប ស្វាយរៀង ព្រៃវែង កំពង់ចាម ត្បូងឃ្មុំ កំពង់ឆ្នាំង បន្ទាយមានជ័យ កណ្ដាល រាជធានីភ្នំពេញ ឧត្តរមានជ័យ និងខេត្តសៀមរាប ។

**1.2. ការងារសវនកម្មគម្រោង៖** នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានចុះធ្វើសវនកម្មលើគម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍ គម្រោងនិរន្តរភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា និងគម្រោងពិពិធកម្មវិស័យកសិកម្មនៅកម្ពុជា ។

### 2. ការតាមដានអនុសាសន៍សវនកម្មផ្ទៃក្នុង និងការអនុវត្តតាមអនុសាសន៍សវនកម្មផ្ទៃក្នុង

- នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានចុះតាមដានសវនកម្មផ្ទៃក្នុងនៅមន្ទីរអភិវឌ្ឍន៍ជនបទចំនួន ១៦ ខេត្ត និង ០១ គម្រោងគឺ កណ្ដាល តាកែវ ព្រះសីហនុ ស្វាយរៀង កំពង់សោម កែប កំពង់ឆ្នាំង ក្រចេះ កំពង់ធំ ត្បូងឃ្មុំ កំពង់ចាម ពោធិ៍សាត់ បាត់ដំបង ព្រះវិហារ មណ្ឌលគីរី រតនគិរី និងគម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍ ។

3. **ការងារសិក្ខាសាលា**

– នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានបើកវគ្គសិក្ខាសាលាផ្សព្វផ្សាយសវនកម្មផ្ទៃក្នុង តាមអនឡាញ ដែលមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីទាំង ២៥ មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត។

4. **ការងារប្រជុំ សិក្ខាសាលា បណ្តុះបណ្តាល និងសន្និបាត**

– ថ្នាក់ដឹកនាំ និងមន្ត្រីបានចូលរួមកិច្ចប្រជុំចំនួន ១២ លើក សិក្ខាសាលាចំនួន ០៨ លើក បណ្តុះបណ្តាលចំនួន ០៥ លើក និងសន្និបាត ០១ លើក។

- **ការងារប្រជុំ**

– លោកប្រធាននាយកដ្ឋាន និងអនុប្រធាននាយកដ្ឋាន ០២រូប បានចូលរួមកិច្ចប្រជុំស្តីពីការរៀបចំគម្រោងស្នើសុំហិរញ្ញប្បទាន ឥតសំណងពីរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ សម្រាប់ឆ្នាំសារពើពន្ធ ២០២៤ ក្រោមអធិបតីភាព **ឯកឧត្តម ម៉ា សុវណ្ណា** ទីប្រឹក្សាអមក្រសួង និងជាប្រធាននាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ ថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ ២០២២ វេលាម៉ោង ១០:០០ នាទីព្រឹក តាមប្រព័ន្ធវីដេអូ (Zoom) ។

– លោកប្រធាននាយកដ្ឋានបានចូលរួមកិច្ចប្រជុំពិនិត្យលទ្ធផល និងពិភាក្សាវាយតម្លៃលើការដាក់បញ្ចូលអង្គភាពថវិកាអាណាប័កពេញលេញ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត សួស គង់** រដ្ឋលេខាធិការប្រចាំការ និងជាប្រធានក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្រសួងអភិវឌ្ឍន៍ជនបទ ថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ២០២២ វេលាម៉ោង ១៥:០០ រសៀល នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ សាលប្រជុំលេខ ៣០៥ ជាន់ទី ៣ ។

– លោកប្រធាននាយកដ្ឋានបានអញ្ជើញអមដំណើរ **ឯកឧត្តម ប៊ុន ច័ន្ទវណ្ណៈ** រដ្ឋលេខាធិការនៃក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីចូលរួមកិច្ចប្រជុំសវនកម្មផ្ទៃក្នុង និងអគ្គាធិការដ្ឋានដែលមានសមត្ថកិច្ចត្រួតពិនិត្យ ប្រជុំជាមួយជំនាញការបារាំង ថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង ០៩:០០ នាទីព្រឹក នៅបន្ទប់ប្រជុំអគារ (គ) ទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

– លោកប្រធាននាយកដ្ឋាន បានដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកុម្ភៈ និងលើកទិសដៅបន្តខែមីនា ឆ្នាំ ២០២២ នាថ្ងៃទី ០២ ខែមីនា ឆ្នាំ ២០២២ វេលាម៉ោង ១៤:០០ រសៀល តាមប្រព័ន្ធវីដេអូ (Zoom) ។

– លោកប្រធាននាយកដ្ឋាន និងអនុប្រធាននាយកដ្ឋាន ០១រូប រួមជាមួយការិយាល័យរដ្ឋបាល និងបុគ្គលិក បានចូលរួមកិច្ចប្រជុំស្តីពី "ការពង្រឹងការគ្រប់គ្រងការងារបុគ្គលិក" ក្រោមអធិបតីភាព **ឯកឧត្តម សាន វិសាល** រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០២២ វេលាម៉ោង ០៨:៣០ នាទីព្រឹក តាមប្រព័ន្ធ Zoom ។

– លោកប្រធាននាយកដ្ឋាន ចូលរួមកិច្ចប្រជុំការងារ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០២២ វេលាម៉ោង ០៩:០០ នាទីព្រឹក នៅសាលាប្រជុំជាន់ទី ៨ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។

- លោកប្រធាននាយកដ្ឋាន និងអនុប្រធាននាយកដ្ឋាន ០១រូប បានចូលរួមប្រជុំពិភាក្សាកម្រិតបច្ចេកទេសលើគម្រោងផែនការចំណូល-ចំណាយថវិកាឆ្នាំ ២០២៣ ក្រោមអធិបតីភាព **ឯកឧត្តម ហួត សារឹម** អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ ២០២២ វេលាម៉ោង ១៥:00 រសៀលនៅសាលប្រជុំជាន់ទី០៣ បន្ទប់ ៣០៥ របស់ក្រសួង អភិវឌ្ឍន៍ជនបទ ។
- លោកប្រធាននាយកដ្ឋាន បានចូលរួមប្រជុំពិភាក្សស្តីពី ការចុះអធិការកិច្ចហិរញ្ញវត្ថុផ្អែកតាមអនុលោមភាព លើការគ្រប់គ្រងអនុវត្តចំណូល-ចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋក្នុងការិយបរិច្ឆេទ ២០២១ និងឆ្នាំពាក់ព័ន្ធ នៅក្រសួងអភិវឌ្ឍន៍ជនបទ និងបណ្តាអង្គភាពថវិកាក្រោមចំណុះ ក្រោមអធិបតីភាព លោកជំទាវ **ហូ សុវណ្ណរិកា រដ្ឋលេខាធិការ** ក្រសួងអភិវឌ្ឍន៍ជនបទ ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០២២ វេលាម៉ោង ៩:០០ ព្រឹក នៅសាលប្រជុំជាន់ទី ៧ បន្ទប់ ៧០៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ។
- លោកអនុប្រធាននាយកដ្ឋាន ០១ រូប និងមន្ត្រីជំនាញ ០១ រូប បានចូលរួមកិច្ចប្រជុំពិភាក្សាអំពីធាតុចូល(Input)ដើម្បីរៀបចំផែនការស្តីពីការងារអភិវឌ្ឍន៍ជនបទអាស៊ានឆ្នាំ ២០២២-២០២៦ ថ្ងៃទី ០៥ ខែសីហា ឆ្នាំ ២០២២ វេលាម៉ោង ២:៣០ នាទីរសៀល នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ សាលប្រជុំជាន់ទី ៣ (បន្ទប់ ៣០៥) ។
- ឯកឧត្តមប្រធាននាយកដ្ឋាន បានចូលរួមប្រជុំពិភាក្សាលើគម្រោងផែនការថវិការបស់ក្រសួងអភិវឌ្ឍន៍ជនបទឆ្នាំ ២០២៣ ថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០២២ វេលាម៉ោង ១៥:០០ នាទីរសៀល នៅសាលប្រជុំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ឯកឧត្តមប្រធាននាយកដ្ឋាន បានបើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកញ្ញា និងលើកទិសដៅការងារខែតុលា ឆ្នាំ ២០២២ ក្រោមអធិបតីភាព **ឯកឧត្តម ជាម ហ៊ីម** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ថ្ងៃទី ០៥ខែតុលា ឆ្នាំ ២០២២ នៅបន្ទប់ ៤១៥ នាយកដ្ឋានសវនកម្មផ្ទៃក្នុង។
- ឯកឧត្តមប្រធាននាយកដ្ឋាន បានចូលរួមកិច្ចប្រជុំពិភាក្សាការងាររៀបចំសេចក្តីព្រាងវិសោធនកម្មលើអនុក្រឹត្យស្តីពីការរៀបចំប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព **ឯកឧត្តម តួច សោភា** រដ្ឋលេខាធិការ ក្រសួងអភីវឌ្ឍន៍ជនបទ នៅថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០២២ វេលាម៉ោង ៩:០០ នាទីព្រឹក នៅសាលាប្រជុំជាន់ទី១ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។

- **សិក្ខាសាលា**

- លោកអនុប្រធាននាយកដ្ឋាន ០២រូប បានចូលរួមសិក្ខាសាលាស្តីពី ការរៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈ(ក.វ.ស.) ៣ឆ្នាំរំកិល ២០២៣-២០២៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត សុខ សារាវុឌ្ឍ** រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០២២ វេលាម៉ោង ០៨:៣០ នាទីព្រឹក នៅសាលាប្រជុំធំជាន់ទី ៨ ទីស្តីការក្រសួង និងតាមប្រព័ន្ធអនឡាញ (Zoom)។

- លោកអនុប្រធាននាយកដ្ឋាន ០១រូប បានចូលរួមសិក្ខាសាលាបូកសរុបលទ្ធផលការងារដែលសម្រេចបានក្នុងឆ្នាំ២០២១ និងលើកទិសដៅការងារបន្ត លើវិស័យផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ ថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២២ នៅសណ្ឋាគារសោន់វ៉េ រាជធានីភ្នំពេញ។
- លោកអនុប្រធាននាយកដ្ឋាន ០១រូប ចូលរួមសិក្ខាសាលាស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៣-២០២៥ និងថវិកាសមិទ្ធកម្ម ឆ្នាំ ២០២៣ របស់ក្រសួងអភិវឌ្ឍន៍ ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០២២ វេលាម៉ោង ០៨:០០ នាទីព្រឹក នៅសណ្ឋាគារឆ្នេរសុខា ខេត្តព្រះសីហនុ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត សួស គង់** រដ្ឋលេខាធិការប្រចាំការ តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ។
- លោកប្រធាននាយកដ្ឋាន និងអនុប្រធាននាយកដ្ឋាន ០១ រូប រួមជាមួយមន្ត្រីជំនាញ ០៤ រូប ចូលរួមសិក្ខាសាលាផ្ទាល់ និងតាមប្រព័ន្ធអនឡាញ Zoom ស្តីពី "ការដាក់ឲ្យប្រើប្រាស់គោលការណ៍ត្រួតពិនិត្យផ្ទៃក្នុងបច្ចេកវិទ្យាព័ត៌មាន" ថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០២២ នៅសណ្ឋាគារភ្នំពេញតាមប្រព័ន្ធ Video Conference "Zoom" ។
- លោកអនុប្រធាននាយកដ្ឋាន ០១ រូប និងមន្ត្រីជំនាញ ០២ រូប បានចូលរួមសិក្ខាសាលា ស្តីពីការផ្សព្វផ្សាយលទ្ធផល នៃការអនុវត្តថវិកាកម្មវិធី ក្រោមអធិបតីភាព **ឯកឧត្តម ហួត សារឹម** អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ដែលប្រព្រឹត្តទៅថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ ២០២២ នៅសណ្ឋាគារខេមរាអង្គរ និងស្ប៉ា ខេត្តសៀមរាប ។
- មន្ត្រីជំនាញចំនួន ០៤ រូប បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាលលើសៀវភៅគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ របស់គ្រោងនិរន្តរភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជារយៈពេល ០៤ ថ្ងៃ ចាប់ពីថ្ងៃទី ០៩-១២ ខែសីហា ឆ្នាំ ២០២២ វេលាម៉ោង ៨:៣០ នាទីព្រឹក នៅសណ្ឋាគារអង្គរមីរ៉ាខល រីសត និងស្ប៉ា ខេត្តសៀមរាប ។
- លោកអនុប្រធាននាយកដ្ឋាន ០១ រូប និងមន្ត្រីជំនាញចំនួន ០២ រូប បានចូលរួមសិក្ខាសាលាស្តីពី " ការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់បិទបញ្ចប់គម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍ " ថ្ងៃទី ១៧-១៨ ខែតុលា ឆ្នាំ ២០២២ នៅសណ្ឋាគារអង្គរមិរ៉ាខល ខេត្តសៀមរាប ។
- ថ្នាក់ដឹកនាំនាយកដ្ឋាន និងមន្ត្រីជំនាញចំនួន ១៥ រូប បានចូលរួមសិក្ខាសាលាស្តីពី " នីតិវិធីនៃការធ្វើសវនកម្មផ្ទៃក្នុង និងការគ្រប់គ្រងហានិភ័យរបស់គម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍ " ថ្ងៃទី ១៥-១៩ ខែវិច្ឆិកា ឆ្នាំ ២០២២ នៅសណ្ឋាគារអង្គរមិរ៉ាខល ខេត្តសៀមរាប។

- **បណ្តុះបណ្តាល**

- លោកអនុប្រធាននាយកដ្ឋាន ០២រូប និងមន្ត្រីជំនាញផែនការ និងហិរញ្ញវត្ថុ ០១ រូប បានចូលរួមក្នុងសិក្ខាសាលាបណ្តុះបណ្តាលស្តីពី គោលការណ៍ណែនាំការរៀបចំថវិកាព័ត៌មានសមិទ្ធកម្មរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត សុខសារាវុឌ្ឍ រដ្ឋលេខាធិការតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ថ្ងៃទី ២៧-២៨ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ០៨:៣០ នាទីព្រឹក នៅសាលប្រជុំធំជាន់ទី ៨ ទីស្តីការក្រសួង និងតាមប្រព័ន្ធអនឡាញ (Zoom) ។

- លោកប្រធាននាយកដ្ឋាន បានចូលរួមវគ្គបណ្តុះបណ្តាលអំពីគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្ម នាថ្ងៃទី ០៩-១១ ខែមីនា ឆ្នាំ២០២២ តាមប្រព័ន្ធអនឡាញ (Zoom) ។
- លោកអនុប្រធាននាយកដ្ឋាន ០១ និងមន្ត្រីជំនាញចំនួន ០១ រូបបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីអភិបាលកិច្ចប្រកបដោយវានុវត្តន៍ នៅមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការកម្ពុជា-សិង្ហបុរី ថ្ងៃទី ២២-២៦ ខែសីហា ឆ្នាំ ២០២២ ។
- លោកអនុប្រធាននាយកដ្ឋាន ០១ រូប និងមន្ត្រីជំនាញចំនួន ០១ រូបបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ភាសាអង់គ្លេសកំរិតខ្ពស់ និងជំនាញសំរាប់ការប្រស្រ័យទាក់ទង (Adavnced English Language and Communication Skills) ដែលនឹងប្រព្រឹត្តិទៅចាប់ពីថ្ងៃទី២៩ ខែសីហា ដល់ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០២២ នៅមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការកម្ពុជា-សិង្ហបុរី (CSCC)។
- លោកស្រីអនុប្រធាននាយកដ្ឋាន ០១ រូប និងមន្ត្រីជំនាញ ០១ រូប បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "នីតិវិធីនៃការអនុវត្តការងារសវនកម្មផ្ទៃក្នុង" ដែលប្រព្រឹត្តទៅនៅថ្ងៃទី ១៩-២១ ខែកញ្ញា ឆ្នាំ ២០២២ តាមរយៈ Zoom Video Conference ។

- **សន្និបាត**

- លោកប្រធាន និងថ្នាក់ដឹកនាំនាយកដ្ឋាន បានចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០២១ និងលើកទិសដៅការងារឆ្នាំ ២០២២ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នាថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០២២ នៅសាលប្រជុំជាន់ទី ៨ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ និងតាមប្រព័ន្ធអនឡាញ (Zoom) ។

5. **កម្មវិធីផ្សេងៗ**

- លោកស្រីអនុប្រធាននាយដ្ឋាន ០១រូប បានចូលរួមក្នុងពិធីបុណ្យមាឃបូជា ដែលប្រារព្ធធ្វើនៅថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០២២ វេលាម៉ោង ០៧:០០ នាទីព្រឹក ក្រោមអធិបតីភាព **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នៅបរិវេណឧបដ្ឋានសាលាមុខព្រះមហាសក្យមុនីចេតិយភ្នំព្រះរាជទ្រព្យ (ឧត្តុង្គ) (ស្រុកពញាឮ)ខេត្តកណ្តាល ។
- លោកស្រីអនុប្រធាននាយកដ្ឋាន និងមន្ត្រីជានារីបានចូលរួមអបអរសាទរទិវាអន្តជាតិនារី ០៨ មីនា ឆ្នាំ ២០២២ ក្រោមមូលបទ "សមភាពយេនឌ័រថ្ងៃនេះ ដើម្បីចីរភាពនាពេលអនាគត" នៅថ្ងៃទី ០៣ ខែមីនា ឆ្នាំ ២០២២ ។
- លោកប្រធាននាយកដ្ឋាន បានចូលរួមជួបសំណេះសំណាល និងការចុះសួរសុខទុក្ខនាយទាហាន នាយទាហានរង និងពលទាហាននៃកងពលតូចថ្មើរជើងលេខ ៥២ ស្ថិតក្នុងស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង ក្រោមអធិបតីភាព **ឯកឧត្តម អ៊ិន ចន្ថា** តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ថ្ងៃទី០១ ខែមេសា ឆ្នាំ ២០២២ ។
- លោកប្រធាននាយកដ្ឋាន បានចូលរួមអបអរសោរទរក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន**

រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ថ្ងៃទី ០៨ ខែមេសា ឆ្នាំ ២០២២ វេលាម៉ោង ១៤:០០ នាទីរសៀល នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ (សាលប្រជុំជាន់ទី ៨) ។

- ឯកឧត្តមប្រធាននាយកដ្ឋាន បានចូលរួមក្នុងពិធីជួបសំណេះសំណាល និងសួរសុខទុក្ខនាយទាហាន នាយទាហានរង និងពលទាហាន ក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរ នៅកងពលតូចថ្មើរជើងលេខ ៥២ ស្ថិតក្នុងស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង ក្រោមអធិបតីភាព **ឯកឧត្តម អ៊ិន ចន្ថា** តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០២២។
- អនុប្រធានការិយាល័យ ០២ រូបបានចូលរួមទទួលគណៈប្រតិភូជាន់ខ្ពស់ ដឹកនាំដោយ **ឯកឧត្តម** DR. JOSE RAMOS-HORTA ប្រធានាធិបតី នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត នៅថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០២២ វេលាម៉ោង ៨:៤០ នាទីព្រឹក នៅមុខព្រះបរមរាជវាំង។
- ឯកឧត្តមប្រធាននាយកដ្ឋាន បានអញ្ជើញចូលរួមដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធ នៅវិមានឯករាជ្យ និងបន្តដំណើរអញ្ជើញទៅថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា** “**ព្រះបរមរតនកោដ្ឋ**” នៅសួនច្បារខាងកើតវិមានឯករាជ្យ ថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ ២០២២។
- ថ្នាក់ដឹកនាំនាយកដ្ឋាន ០៨ រូប បានចូលរួមពិធីប្រទានភ្លើងជ័យ ថ្ងៃទី ០៩ ខែវិច្ឆិកា ឆ្នាំ ២០២២ និងពិធីពន្លត់ភ្លើងជ័យ ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០២២ នៅវិមានឯករាជ្យ ក្រោមព្រះរាជាធិបតីភាព **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។
- លោកស្រីអនុប្រធាននាយកដ្ឋាន ០១រូប និងអនុប្រធានការិយាល័យ ០១ រូបបានចូលរួមទទួលគណៈប្រតិភូជាន់ខ្ពស់ ដឹកនាំដោយ **ព្រះចៅស៊ុលតង់** HAJI HASSANAL BOLKIAH ព្រះមហាក្សត្រ និងជាព្រះប្រមុខរដ្ឋ នៃប្រទេសព្រុយណេ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ២០២២ នៅមុខព្រះបរមរាជវាំង។
- ថ្នាក់ដឹកនាំនាយដ្ឋាន ០៣ រូប បានចូលរួមពិធីបើកកីឡាជាតិ លើកទី ៣ ឆ្នាំ ២០២២ ក្រោមអធិបតីភាព សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០២២ នៅពហុកីឡាដ្ឋានជាតិមរតកតេជោ។

## III. ភាពងាយស្រួល និង ការលំបាក

### 1. ភាពងាយស្រួល

- មានការជំរុញលើកទឹកចិត្តគាំទ្រទាំងសម្ភារៈ និងស្មារតីពីថ្នាក់ដឹកនាំក្រសួងជាពិសេសពី **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី**
- មន្ត្រីមានស្មារតីខ្ពស់ក្នុងការចូលរួមអភិវឌ្ឍសមត្ថភាព។

### 2. ការលំបាក

- សមត្ថភាពយល់ដឹងក្នុងការធ្វើសវនកម្មលើជំនាញមួយចំនួន និងតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅមានកម្រិត
- មន្ត្រីសវនករថ្មីមិនទាន់យល់ដឹងទូលំទូលាយលើផ្នែកសវនកម្ម ។

## IV. ទិសដៅការងារបន្ត និងសំណូមពរ

- បំពេញភារកិច្ចឲ្យបានជោគជ័យតាមផែនការ និងត្រៀមខ្លួនអនុវត្តតាមអនុសាសន៍ដឹកនាំរបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី**
- ត្រៀមខ្លួនចូលរួមក្នុងការពង្រឹងសមត្ថភាពបន្ថែមទៀត។

## V. សេចក្តីសន្និដ្ឋាន

ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង មានលក្ខណៈល្អប្រសើរដែលធ្វើឲ្យសកម្មភាពចុះត្រួតពិនិត្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។

បានឃើញ សូមគោរពជូន

**ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី**

មេត្តាជ្រាបជារបាយការណ៍

ដ៏ខ្ពង់ខ្ពស់ ដោយសេចក្តីអនុគ្រោះ ។

ថ្ងៃពុធ ១៥រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ត្រូវនឹង ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០២២

**ប្រធាននាយកដ្ឋាន**

**អ្នកធ្វើរបាយការណ៍**

**យ៉ាន់ បូរិន**

**ចម្លងជូន ៖**

- ខុទ្ទកាល័យ ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី
- រដ្ឋលេខាធិការទទួលបន្ទុក
- អនុរដ្ឋលេខាធិការទទួលបន្ទុក
- អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកបច្ចេកទេស
- នាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ
- ឯកសារ-កាលប្បវត្តិ